ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ០៥ អយក.សរណន

# សារាចរណែនាំ

## ស្តីពី

## ការផ្តល់អាហារូបករណ៍ ( រៀនមិនបង់ថ្លៃ ) ចំពោះនិស្សិតអាទិភាព ក្នុងការចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ សំរាប់ឆ្នាំសិក្សា ២០០៣-២០០៤

***&***

**យោង** : -ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

-ប្រកាសលេខ ៤៥០ អយក.ប្រក ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីបទបញ្ញាជ្រើសរើសនិស្សិតអោយចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា

-ប្រកាសលេខ ៧៦ អយក.ប្រក ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការកំនត់តំបន់ជួបការលំបាក

-ការសំរេចរបស់អង្គប្រជុំនៅក្រសួងអប់រំ យុវជន និង កីឡា នាថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៣

កន្លងមកការជ្រើសរើសនិស្សិតអោយទទួលអាហារូបករណ៍ចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ត្រូវបានបែងចែកកន្លែងមួយចំនួនសំរាប់និស្សិតដែលមានអាទិភាព ប៉ុន្តែការជ្រើសរើសនេះ ក្រសួងបានសង្កេតឃើញថា មានគ្រឹះស្ថានសិក្សាខ្លះអនុវត្តបានល្អ តែក៏មានគ្រឹះស្ថានសិក្សាខ្លះអនុវត្តនៅពុំទាន់បានល្អនៅឡើយ ។ ដើម្បីសំរួលដល់ការជ្រើសរើស និង ដើម្បីអោយមានការឯកភាពគ្នាពីគ្រឹះស្ថានសិក្សាមួយទៅគ្រឹះស្ថានសិក្សាមួយទៀត ចំពោះការផ្តល់អាហារូបករណ៍ដល់និស្សិតដែលមានអាទិភាព ក្រសួងសូមធ្វើការណែនាំដូចខាងក្រោម :

១-និស្សិតអាទិភាពត្រូវបានកំនត់ជា៣ប្រភេទ :

ប្រភេទទី១ : និស្សិតក្រីក្រ

ប្រភេទទី២ : និស្សិតជនជាតិភាគតិច និងនិស្សិតរស់នៅក្នុងខេត្តក្រុងដាច់ស្រយាល រឺតំបន់ជួបការលំបាក

ប្រភេទទី៣ : និស្សិតជានារីភេទ

២-ចំនួនភាគរយ នៃកន្លែងអាហារូបករណ៍សំរាប់និស្សិតអាទិភាព នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ នីមួយៗមាន ៣០% នៃចំនួនកន្លែងអាហារូបករណ៍សរុប ដែលត្រូវបានបែងចែក

ដូចខាងក្រោម ៖

-និស្សិតក្រីក្រ ១០%

-និស្សិតជនជាតិភាគតិច និងនិស្សិតមកពីខេត្តក្រុងដាច់ស្រយាលរឺតំបន់ជួបការលំបាក១០%

-និស្សិតជានារីភេទ ១០%

៣-និស្សិតក្រីក្រត្រូវមានចំនុចសំគាល់ជាមូលដ្ឋាន ដូចខាងក្រោម ៖

-ឪពុក និង ម្តាយស្លាប់

-ឪពុក រឺ ម្តាយស្លាប់

-ឪពុក រឺ ម្តាយនៅរស់តែចូលនិវត្តន៍ រឺ ចាស់ជរា

-ឪពុក រឺ ម្តាយជាយោធិនរំសាយ រឺ ពិការ

-ឪពុក រឺ ម្តាយជាកម្មករ រឺ កសិករក្រកមួយថ្ងៃសំរាប់មួយថ្ងៃ

-មានបងប្អូនបង្កើតចាប់ពី ៥នាក់ឡើងដែលពុំមានការងារធ្វើ

-សព្វថ្ងៃស្នាក់នៅតាមវត្តអារាម រឺ មណ្ឌលកុមារកំព្រា រឺ ផ្ទះមិត្តភក្តិសាច់ញាតិ

-ក្រុមគ្រួសារមានដីធ្លីមិនលើសពី៣០ម៉ែត្រក្រឡា

-គ្មានគេរ្តីមរតក

-មានមធ្យោបាយធ្វើដំណើរត្រឹមតែរទេះគោ រឺ កង់ រឺ ថ្មើរជើង

-ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារមានកំរិតទាបជាងមួយលានរៀល

-ពុំមានមិត្តភក្តិ , ញាតិ រឺ អ្នកណាមួយជួយផ្តល់ប្រាក់ក្នុងការរស់នៅ និង រៀនសូត្រ

៤-និស្សិតជាជនជាតិភាគតិច ៖ ជាជនជាតិដែលមានដើមកំណើតនៅខេត្ត-ក្រុង ដាច់ស្រយាល និង បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅទីនោះ

៥-និស្សិតមកពីតំបន់ដាច់ស្រយាល ៖ ជានិស្សិតដែលមានដើមកំនើតមកពីតំបន់ដាច់ស្រយាល រឺ តំបន់ជួបការលំបាក ហើយបានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិនៅទីនោះ

៦-ខេត្ត-ក្រុងដាច់ស្រយាល និង តំបន់ជួបការលំបាក ៖

ក- ខេត្ត-ក្រុងដាច់ស្រយាលរួមមាន ៖ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកោះកុង និង ក្រុងប៉ៃលិន

ខ-តំបន់ក្នុងខេត្ត-ក្រុងដែលកំនត់ជាតំបន់ជួបការលំបាក ៖

- <u>ខេត្តពោធិសាត់ មាន</u> ៖ ស្រុកភ្នំក្រវាញ ស្រុកវាលវែង

  ស្រុកបាកាន ៖ ឃុំតាលោ

  ស្រុកក្រគរ ៖ ឃុំឈើតុំ និង ឃុំស្វាយស

- <u>ខេត្តកំពង់ធំ មាន</u> : ស្រុកសណ្តាន់ ស្រុកប្រាសាទសំបូរ ស្រុកប្រាសាទបល្ល័ង្គ

ស្រុកកំពង់ស្វាយ : ឃុំផាត់សណ្តាយ ឃុំទីពោជ ឃុំដំរីស្លាប់ និង ឃុំជ័យ

ស្រុកស្ទោង : ឃុំពាមបាង ឃុំពពក ឃុំបន្ទាយស្ទោង ឃុំចំណារលើ និង ឃុំព្រះដំរី

ស្រុកបារាយណ៍ : ឃុំគគីធំ និង ឃុំបាក់ស្នា

ស្រុកសន្ទុក : ឃុំទីពោ និង ឃុំក្រយា

- <u>ខេត្តបាត់ដំបងមាន</u> : ស្រុករតនៈមណ្ឌល ស្រុកបវេល ស្រុកសំពៅលូន ស្រុកភ្នំព្រឹក្ស

ស្រុកកំរៀង ស្រុកគាស់ក្រឡ ស្រុកសំឡូត

ស្រុកឯកភ្នំ : ឃុំកោះជីវាំង និង ឃុំព្រៃចាស់

ស្រុកមោងឫស្សី : ឃុំព្រៃត្រឡាច

- <u>ខេត្តសៀមរាប មាន</u> : ស្រុកស្រីស្នំ ស្រុកស្វាយលើ ស្រុកវ៉ារិន ស្រុកអង្គជុំ ស្រុកអង្គរធំ

ស្រុកបន្ទាយមានជ័យ : ឃុំឃុនរាម ឃុំរំចេក ឃុំត្បែង និង ឃុំរន្ធតាអក

ស្រុកជីក្រែង : ឃុំអន្លង់សំណរ ឃុំខ្នារ ឃុំគោកធ្លកលើ ឃុំពង្រលើ ឃុំពង្រក្រោម ឃុំឫស្សីលក ឃុំល្វែងឫស្សី ឃុំស្ពានត្នោត និង ឃុំសង្វើយ

ស្រុកក្រឡាញ់ : ឃុំរោងគោ ឃុំស្នួល ឃុំក្រូចគោ ឃុំសែនសុខ និង ឃុំសំបូរ

ស្រុកសូត្រនិគម : ឃុំពពេល ឃុំចាន់សរ ឃុំខ្នាពោធិ ឃុំតាយ៉ែតនិង ឃុំកំពង់ឃ្លាំង

ស្រុកពួក : ឃុំកែវពិណ ឃុំរើល ឃុំត្រីញ័រ ឃុំល្វា ឃុំយាង ឃុំគ្គីរន ឃុំពោធិទ្រាយ និង ឃុំដូនកែវ

ស្រុកសៀមរាប : ឃុំនគរធំ និង ឃុំចុងឃ្នៀស

ស្រុកប្រាសាទបាគង : ឃុំអំពិល ឃុំបាល័ង្គ និង ឃុំកំពង់ភ្លុក

- <u>ខេត្តកំពង់ចាម មាន</u> : ស្រុកតំបែរ

ស្រុកមេមត់ : ឃុំទ្រាក ឃុំរូង ឃុំចាន់មូល ឃុំជាំក្រវៀន ឃុំទន្លូង ឃុំជាំតាម៉ៅ ឃុំជាំ ឃុំត្រម៉ោង ឃុំមេមង ឃុំគគីរ ឃុំកំពាន់ ឃុំរំចេក និង ឃុំរូង

ស្រុកស្ទឹងត្រង់ : ឃុំអូរម្លូ ឃុំដងក្ដារ ឃុំអារក្សត្នោត និង ឃុំ ខ្ពបតាងួន

ស្រុកចំការលើ : ឃុំតាប្រុក និង ឃុំចំការអណ្តូង

ស្រុកត្បូងឃ្មុំ : ឃុំថ្មពេជ្រ ឃុំគរ ឃុំល្មៀង និង ឃុំ រកាពប្រាំ

ស្រុកពញាក្រែក : ឃុំវាលម្លូ ឃុំកក់ និង ឃុំត្រពាំងផ្លុង

- ខេត្តបន្ទាយមានជ័យ មាន : ស្រុកម៉ាឡៃ ស្រុកថ្មពួក ស្រុកភ្នំស្រុក

ស្រុកព្រះនេត្រព្រះ : ឃុំរហាល ឃុំទឹកជោរ ឃុំប្រាសាទ ឃុំទានកាំ និង ឃុំភ្នំលៀប

ស្រុកស្វាយចេក : ឃុំផ្គាំ ឃុំតាផូ ឃុំស្វាយចេក ឃុំសារង្គ ឃុំស្លក្រាម ឃុំទ្រាល
ឃុំតាបែន និង ឃុំរលួស

ស្រុកអូរជ្រៅ : ឃុំអូរបីជាន់ ឃុំនិមិត្ត ឃុំសឹង្ហ ឃុំសំរោង និង ឃុំប៉ោយប៉ែត

ស្រុកសិរីសោភ័ណ : ឃុំបុសស្បូវ

ស្រុកមង្គលបូរី : ឃុំសំបួរ ឃុំ[illegible]កបល័ង្គ ឃុំសឿ និង ឃុំចំណោម

- ខេត្តកំពង់ស្ពឺ មាន : ស្រុកថ្ពង់ ស្រុកឱរ៉ាល់

ស្រុកភ្នំស្រួច : ឃុំទាំងអស់នៅក្នុងស្រុកភ្នំស្រួច លើកលែងតែ ឃុំមហាសាំង

ស្រុកបរសេដ្ឋ : ឃុំកាត់ភ្លុក ឃុំភក្តី ឃុំកក់ និង ឃុំព្រះខែ

ស្រុកសំរោងទង : ឃុំទំព័រមាស និង ឃុំតាំងក្រូច

ស្រុកឧត្តុង្គ : ឃុំជម្ពូព្រឹក្ស

- ខេត្តក្រចេះ មាន :

ស្រុកស្នួល : ឃុំស្រែចារ និង ឃុំខ្សឹម

ស្រុកសំបូរ : ឃុំរលួស ឃុំស្រែជិះ ឃុំបឹងចារ ឃុំអូរគ្រៀង និង ឃុំក្បាលដំរី

ស្រុកឆ្លូង : ឃុំកំពង់ដំរី និង ឃុំដំរីផុង

- ខេត្តកំពត មាន : ស្រុកដងទង ស្រុក ជុំគិរី

ស្រុកឈូក : ឃុំល្បើក ឃុំត្រពាំងឃ្លាំង និង ឃុំតាកែន

ស្រុកកំពត : ឃុំស្ទឹងកែវ និង ឃុំព្រៃថ្នង់

ស្រុកកំពង់ត្រាច: ឃុំឫស្សីស្រុកខាងកើត ឃុំបឹងសាលាខាងត្បូង ឃុំបឹងសាលាខាងជើង
និង ឃុំព្រែកក្រើស

ស្រុកបន្ទាយមាស : ឃុំត្នោតចុងស្រង់ ឃុំព្រៃទន្លេ ឃុំបន្ទាយមាសខាងលិច ឃុំបន្ទាយ
មាសខាងកើត និង ឃុំស្តេចគង់ខាងត្បូង

- ខេត្តតាកែវ មាន : ស្រុកបូរីជលសារ ស្រុកកោះអណ្តែត ស្រុកអង្គរបូរី

ស្រុកគិរីវង់ : ឃុំកំណប់ ឃុំសោម ឃុំតាអូ ឃុំកំពែង និង ឃុំគោកព្រេច

ស្រុកទ្រាំង : ឃុំអង្គកែវ ឃុំខ្វាវ ឃុំរនាម ឃុំធ្លក និង ឃុំសំបូរ

ស្រុកត្រាំកក់ : ឃុំអូរសោភាយ និង ឃុំត្រពាំងក្រញូង

ស្រុកព្រៃកប្បាស : ឃុំកំពង់រាប

- <u>ខេត្តកណ្តាល មាន</u> :

ស្រុកលើកដែក : ឃុំក្តមសំណ និង ឃុំសណ្តារ

ស្រុកកោះធំ : ឃុំព្រែកជ្រៃ ឃុំសំពៅពូន និង ឃុំលើកដែក

ស្រុកស្អាង : ឃុំប្រាសាទ និង ឃុំព្រែកអំបិល

ស្រុកល្វាឯម : ឃុំបារុង ឃុំព្រៃឫស្សី ឃុំកោះកែវ និង ឃុំសំបូរ

ស្រុកមុខកំពុល : ឃុំសំបូរមាស និង ឃុំស្វាយអំពារ

ស្រុកខ្សាច់កណ្តាល : ឃុំជ្រៃធំ និង ឃុំរកាជន្លឹង

ស្រុកពញាឮ : ឃុំកំពង់លួង ឃុំកោះចិន ឃុំកំពង់អុស និង ឃុំសំរោង

- <u>ខេត្តព្រៃវែង មាន</u> :

ស្រុកព្រះស្តេច : ឃុំបន្ទាយចក្រី និង ឃុំព្រះស្តេច

ស្រុកពាមជរ : ឃុំក្រាំងតាយ៉ង ឃុំកោះសំពៅ និង ឃុំកោះរការ

ស្រុកកំពង់ត្របែក : ឃុំពាមមន្ទា ឃុំជាងដែក និង ឃុំចាម

ស្រុកពារាំង : ឃុំមេសប្រចាន់

ស្រុកស៊ីធរកណ្តាល : ឃុំព្រៅទីពីរ

- <u>ខេត្តកំពង់ឆ្នាំង មាន</u> : ស្រុកទឹកផុស ស្រុកសាមគ្គីមានជ័យ ស្រុកជលគីរី

ស្រុកកំពង់ត្រឡាច : ឃុំអំពិលទឹក

ស្រុកកំពង់លែង : ឃុំផ្លូវទឹក ឃុំប្រឡាយមាស ឃុំច្រនូក និង ឃុំសំរោងសែន

ស្រុករលាប្អៀរ : ឃុំប្រស្និប

ស្រុកបរិបូរណ៍ : ឃុំកំពង់ព្រះ ឃុំគគីរ ឃុំអញ្ចាញរូង ឃុំប្រពេចចង្វារ និង ឃុំត្រពាំងចាន់

- <u>ខេត្តស្វាយរៀង មាន</u> :

ស្រុកចន្ទ្រា : ឃុំសំរោង ឃុំទូលស្តី និង ឃុំចន្ទ្រា

ស្រុកស្វាយទាប : ឃុំមនោរម្យ និង ឃុំព្រៃតាអ៊ី

ស្រុករមាសហែក : ឃុំគគីរ ឃុំត្រស់ ឃុំអណ្តូងត្របែក និង ឃុំសម្បត្តិមានជ័យ

- <u>ក្រុងកែប មាន</u> : ខ័ណ្ឌកែប និង ខ័ណ្ឌដំណាក់ចង្អើរ

- <u>ក្រុងព្រះសីហនុ មាន</u> : ខ័ណ្ឌមិត្តភាព : សង្កាត់កោះរុង

ខ័ណ្ឌព្រៃនប់ : សង្កាត់ព្រៃនប់

៧-ការកំណត់អាទិភាពចំពោះខេត្តក្រុងដាច់ស្រយាល និង តំបន់ជួបការលំបាក :

អាទិភាពទី១ : ខេត្តក្រុងដាច់ស្រយាល ដូចមានក្នុងចំនុច " ៦.ក"

អាទិភាពទី២ : ភូមិ ឃុំ ស្រុកជួបការលំបាកនៃខេត្តមួយចំនួនដូចមានក្នុងចំនុច " ៦.ខ"

៨-វិធីជ្រើសរើស :

ក-គ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវកំណត់និទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប ក្នុងកំរិតមួយសមស្របដែលអាចទទួលយកបាន សំរាប់និស្សិតក្រីក្រ និស្សិតជនជាតិភាគតិច និង និស្សិតមកពីខេត្តក្រុងដាច់ស្រយាល រឺ តំបន់ជួបការលំបាក ។

ខ-សំរាប់និស្សិតក្រីក្រ : ត្រូវផ្អែកលើនិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុប ដែលបានកំណត់ដូច ក្នុងចំនុច៨.ក និង គួបផ្សំជាមួយចំនុចសំគាល់ អំពីភាពក្រីក្រដែលមានក្នុងចំនុច ៣ ។ និស្សិតណាដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេ ហើយមានចំនុចសំគាល់អំពីភាពក្រីក្រច្រើនជាងគេ ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងគេក្នុងការទទួលអាហារូបករណ៍ ។

គ-សំរាប់និស្សិតជនជាតិភាគតិច និង និស្សិតមកពីខេត្ត-ក្រុងដាច់ស្រយាល រឺ តំបន់ជួប ការលំបាក : ត្រូវផ្អែកលើនិទ្ទេសតាមមុខវិជ្ជា និងនិទ្ទេសសរុបដែលបានកំណត់ដូចក្នុងចំនុច ៨.ក និង គួបផ្សំជាមួយចំនុចអាទិភាពនៅតំបន់ដាច់ស្រយាលតំបន់ជួបការលំបាកអាចគួបផ្សំបន្ថែមនូវចំនុចក្រីក្រ ។ និស្សិតណា ដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេ ហើយមានស្ថានភាពភូមិសាស្ត្ររស់នៅ និងក្រីក្រលំបាកជាងគេ ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងគេ ក្នុងការទទួលអាហារូបករណ៍ ។

ឃ-សំរាប់និស្សិតជានារីភេទ : និស្សិតនារីដែលបានកំនត់ថាធ្លាក់ក្នុងពេលជ្រើសរើសផ្អែកនិស្សិតទូទៅនៅក្នុងមុខជំនាញណាមួយ ហើយដែលមាននិទ្ទេសតាមមុខវិជ្ជា និង និទ្ទេសសរុបខ្ពស់ជាងគេក្នុងចំនួនកំនត់យកផ្អែកអាទិភាពនារី លើមុខជំនាញនោះ ត្រូវបានចាត់ទុកថា បានជាប់ទទួលអាហារូបករណ៍ផ្អែកអាទិភាពនារី ក្នុងមុខជំនាញនោះ ។

ង-ក្នុងករណីជ្រើសរើស នៅក្នុងប្រភេទអាទិភាពណាមួយពុំបានគ្រប់ចំនួន ១០% ចំនួនដែលនៅសល់ត្រូវ បន្ថែមទៅក្នុងអាទិភាពផ្សេងៗទៀត តែចំនួនភាគរយសរុប នៃកន្លែងអាហារូបករណ៍សំរាប់និស្សិត អាទិភាពមិនអោយលើសពី ៣០% នៃចំនួនកន្លែងអាហារូបករណ៍សរុបឡើយ ។

ច-គណៈកម្មការជ្រើសរើសត្រូវធ្វើការថ្លឹងថ្លែង និង សំរេចអោយបានត្រឹមត្រូវដោយផ្អែកលើសំណុំឯកសាររបស់បេក្ខជនដែលមានការបញ្ជាក់ពីសមត្ថកិច្ចរដ្ឋអំណាច ។ សំណុំឯកសាររបស់បេក្ខជនដែលគ្មានការបញ្ជាក់ត្រឹមត្រូវពីសមត្ថកិច្ច រដ្ឋអំណាចត្រូវចាត់ទុកថា គ្មានបានការ ។

បន្ទាប់ពីបានទទួលសារាចរណែនាំនេះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដែលធ្វើការជ្រើសរើសនិស្សិតអាទិភាពអោយទទួលអាហារូបករណ៍ចូលរៀនថ្នាក់ឆ្នាំទី១ ត្រូវអនុវត្តដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ។/

ភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៣

ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

អ៊ឹម សិទ្ធី

**កន្លែងទទួល :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-អគ.ឧបរ - អគ.រហ

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា "ដើម្បីជ្រាបជាពត៌មាន"

-គ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ : ន.ឧស